# សមាជិកសភាអឺរ៉ុប ធ្វើដំណើរទៅសហរដ្ឋអាមេរិក ដើម្បីចូលរួមកិច្ចប្រជុំរបស់អង្គការសហប្រជាជាតិស្តីពីស្ថានភាពស្ត្រី និងកិច្ចប្រជុំពិភាក្សាអំពីសិទ្ធិស្ត្រី

ថ្ងៃអាទិត្យ ៦រោច ខែផល្គុន ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៣

គណៈប្រតិភូគណៈកម្មាធិការសិទ្ធិស្ត្រី និងសមភាពយេនឌ័ររបស់សភាអឺរ៉ុប ដឹកនាំដោយលោកRobert Biedron បានធ្វើដំណើរទៅសហរដ្ឋអាមេរិក ដើម្បីចូលរួមសម័យប្រជុំលើកទី៦៧ របស់គណៈកម្មការស្ថានភាពស្ត្រីរបស់អង្គការសហប្រជាជាតិ ដែលប្រព្រឹត្តិទៅក្នុងបុរីញូវយ៉ក និងចូលរួមកិច្ចប្រជុំទ្វេភាគីជាច្រើន ជាមួយតំណាងអង្គការសហប្រជាជាតិ សហភាពអឺរ៉ុប រដ្ឋជាសមាជិកសហភាពអឺរ៉ុប និងសង្គមស៊ីវិល ដែលប្រព្រឹត្តិទៅក្នុងរដ្ឋធានីវ៉ាស៊ីនតោន ពីថ្ងៃទី៦ ដល់ថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៣។

សម័យប្រជុំលើកទី៦៧ របស់គណៈកម្មការស្ថានភាពស្ត្រីរបស់អង្គការសហប្រជាជាតិឆ្នាំនេះ ផ្តោតការយកចិត្តទុកដាក់លើនវានុវត្តភាព ការរីកចម្រើននៃបច្ចេកវិទ្យា និងការអប់រំក្នុងយុគសម័យឌីជីតាល់ ដើម្បីសម្រេចឱ្យបានសមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រី និងក្មេងស្រីគ្រប់រូប។ បន្ទាប់ពីកិច្ចប្រជុំក្នុងបុរីញូវយ៉កថ្ងៃទី៦-៨ ខែមីនា នៅថ្ងៃទី៩ ខែមីនា គណៈប្រតិភូបានធ្វើដំណើរទៅរដ្ឋធានីវ៉ាស៊ីនតោន ដើម្បីប្រជុំជាមួយរដ្ឋបាលរបស់សហរដ្ឋអាមេរិក សមាជិកសភាសហរដ្ឋអាមេរិក និងសង្គមស៊ីវិល។ ប្រធានបទនៃកិច្ចប្រជុំទាំងអស់របស់គណៈប្រតិភូសភា រួមមាន៖

- ប្រធានបទនៃសម័យប្រជុំលើកទី៦៧ របស់គណៈកម្មការស្ថានភាពស្ត្រីរបស់អង្គការសហប្រជាជាតិ៖ ការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ចឌីជីតាល់, ការអភិវឌ្ឍប្រាជ្ញាសិប្បនិម្មិតដោយមិនលម្អៀងយេនឌ័រ, ការប្រយុទ្ធប្រឆាំងអំពើហិង្សាលើប្រព័ន្ធអ៊ីនធឺណិត និងការអប់រំនិងការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រី ក្នុងវិស័យSTEM(វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា)។
- វិធីសាស្ត្រប្រយុទ្ធប្រឆាំងនឹងប្រតិកម្មអវិជ្ជមានធ្ងន់ធ្ងរទូទាំងពិភពលោកចំពោះសិទ្ធិស្ត្រី,លទ្ធភាពទទួលបានសុខភាពផ្លូវភេទនិងសុខភាពបន្តពូជ ដែលក្នុងនោះរួមមាន សុវត្ថិភាពនិងភាពស្របច្បាប់ក្នុងការពន្លូតកូន, អំពើហិង្សាលើភេទ និងការប្រើប្រាស់ទង្វើចាប់រំលោភជាអាវុធធ្វើសង្គ្រាម, ការប្រយុទ្ធប្រឆាំងអំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ និងកិច្ចសហប្រតិបត្តិការទ្វេភាគីនិងពហុភាគីរបស់សហភាពអឺរ៉ុប ដើម្បីលើកកម្ពស់សមភាពយេនឌ័រ និងសិទ្ធិស្ត្រី។

លោកRobert Biedron បានកត់សម្គាល់ថា៖″សហភាពអឺរ៉ុប និងអង្គការសហប្រជាជាតិ មានការព្រួយបារម្ភដូចគ្នា និងផ្តល់អាទិភាពដូចគ្នាពាក់ព័ន្ធនឹងសមភាពយេនឌ័រ និងសិទ្ធិស្ត្រី។ ពាក់ព័ន្ធនឹងស្ថាន-

ភាពនាពេលថ្មីៗចុងក្រោយ ដែលប៉ះពាល់ដល់សមភាពយេនឌ័រនិងសិទ្ធិស្ត្រី ក្នុងសហភាពអឺរ៉ុបនិងទូទាំងពិភពលោក យើងចាំបាច់ត្រូវបង្កើនឱ្យបានខ្លាំងជាងពេលមុនៗ នូវការសហការគ្នានិងការធ្វើសកម្មភាពរួមគ្នា។ យើងចាំបាច់ត្រូវបង្កើតស្តង់ដាសិទ្ធិស្ត្រី ក្នុងកម្រិតអន្តរជាតិ។ សហភាពអឺរ៉ុបចង់នាំមុខគេ ក្នុងការធ្វើជាគំរូ ក្នុងការថ្កោលទោសសកម្មភាពដែលធ្វើឱ្យអាប់ឱនដល់សមភាពយែនឌ័រ តាមរយៈការផ្តល់អំណាចដល់ស្ត្រីនិងក្មេងស្រីគ្រប់រូប និងសម្រេចឱ្យបាននូវសមភាពយេនឌ័រ នៅក្នុងដំណើរការនៃការរីកចម្រើនប្រព័ន្ធឌីជីតាល់។ យើងត្រូវកសាងនូវសេដ្ឋកិច្ចឌីជីតាល់ដែលប្រកបដោយបរិយាប័ន្ន និងប្រយុទ្ធប្រឆាំងនឹងអំពើហិង្សដែលពាក់ព័ន្ធនឹងយេនឌ័រ លើប្រព័ន្ធអ៊ីនធឺណិត។ សកម្មភាពដែលយើងចាត់ទុកថាខុសច្បាប់នៅក្រៅប្រព័ន្ធអ៊ីនធឺណិត ក៏ត្រូវតែចាត់ទុកជាសកម្មភាពខុសច្បាប់ដែរ នៅលើប្រព័ន្ធអ៊ីនធឺណិត។ នៅក្នុងកិច្ចប្រជុំក្នុងបុរីញូវយ៉ក យើងបានពិភាក្សាអំពីលទ្ធផលសម័យប្រជុំលើកទី៦៧ របស់គណៈកម្មការស្ថានភាពស្ត្រីរបស់អង្គការសហប្រជាជាតិ។ យើងសង្ឃឹមថា លទ្ធផលទាំងនោះនឹងនាំមកនូវសកម្មភាពដ៏រឹងមាំ និងមិនធ្វើឱ្យអន់ថយដល់វឌ្ឍនភាព ដែលមានរួចជាស្រេចមកហើយ លើស្ថានភាពសិទ្ធិស្ត្រី។ ហើយយើងក៏សង្ឃឹមផងដែរថា សិទ្ធិមនុស្សនឹងត្រូវបានគេគិតស្របគ្នា ពេលគិតដល់ការអភិវឌ្ឍ។ ក្នុងកិច្ចប្រជុំក្នុងរដ្ឋធានីវ៉ាស៊ីនតោន គណៈប្រតិភូបានបង្ហាញជំហររបស់ខ្លួនថា សុខភាពផ្លូវភេទនិងសុខភាពបន្តពូជ គឺជាសិទ្ធិជាមូលដ្ឋានដែលត្រូវតែទទួលបានការការពារ ហើយគណៈប្រតិភូក៏បានជម្រាបផងដែរអំពីការគាំទ្រនិងសាមគ្គីភាពដ៏របស់រឹងមាំរបស់ខ្លួនចំពោះស្ត្រី និងក្មេងស្រីក្នុងសហរដ្ឋអាមេរិក៕

*ព័ត៌មានពីអង្គការសភា ១២-០៣-២៣- តូនី*

ប្រែសម្រួលពីៈ https://www.europarl.europa.eu/news/en/press-room/20230306IPR77016/new-york-and-washington-d-c-meps-

# NEW YORK AND WASHINGTON, D.C.: MEPS ATTENDED UN CSW AND DISCUSSED WOMEN´S RIGHTS

PRESS RELEASES

Yesterday

**On 6-9 March, a delegation of the Women´s Rights and Gender Equality Committee attended the UN Commission on the Status of Women and held meetings in Washington, D.C. on women´s rights.**

Led by the Chair Robert Biedroń, the delegation attended the 67th session of the UN Commission on the Status of Women (CSW) and held bilateral meetings with representatives of the UN, the EU, member states and civil society on 6-8 March 2023 in New York.

The CSW67 focusses this year on innovation, technological change and on education in the digital age for achieving gender equality and the empowerment of all women and girls. The delegation then travelled to Washington, D.C., where MEPs held meetings with representatives of the US administration, the US Congress and civil society on women´s rights on 9 March 2023.

Subjects that were touched upon during all of the delegation´s meetings in the US were:

- the priority theme of the CSW67: participation of women in the digital economy, development of artificial intelligence in a gender non-biased way, combating cyberviolence, and education and empowerment of women and girls in the STEM sector;
- how to combat the global backlash against women´s rights, access to sexual and reproductive health and rights including safe and legal abortion, sexual violence in conflict and use of rape as weapon of war, the fight against gender based violence, including cyberviolence, as well as sexuality and relationship education for boys, and EU bilateral and multilateral cooperation to advance gender equality and women´s rights.

**Quote**

Robert Biedroń (S&D, Poland), said: "EU and UN priorities and concerns are the same in the area of gender equality and women´s rights. In light of the current backlash against gender equality across the EU and worldwide, our common actions and joint forces are needed more than ever. We need to standardise women´s rights at international level. The EU wants to lead by example by denouncing

this backlash, by empowering women and girls in all their diversity and achieving gender equality in the digital transformation.

We need to build an inclusive digital economy and combat gender-based cyberviolence. Everything that is illegal offline must be illegal online. At our meetings in New York, we discussed the negotiations of the conclusions of the CSW67 and we hope they will be strong, will not water down already achieved progress on women´s rights and will combine a development and a human rights approach.

In our meetings in Washington D.C., we expressed our position that sexual and reproductive health and rights are fundamental human rights which must be protected and we expressed our firm solidarity with and support for women and girls in the US.˝